**ព្រះរាជសុន្ទរកថា**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់វិមានសាមគ្គីភាព(អគារថ្មីនៃព្រឹទ្ធសភា)
**ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៦**

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ **ព្រះមហាក្សត្រ** ជាទីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់
- **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ជាទីរាប់អានដ៏ខ្ពង់ខ្ពស់
- **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី** ជាទីរាប់អានដ៏ខ្ពង់ខ្ពស់
- សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ជាទីស្រឡាញ់រាប់អាន
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ**ខ្ញុំ** មានហឫទ័យប្រកបដោយបីតិសោមនស្សក្រៃលែង ដែលបានចូលរួមជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងព្រះរាជពិធីសម្ពោធ "**វិមានសាមគ្គីភាព**" ដ៏ល្អវិចិត្រ ដែលជាសមិទ្ធផលក្នុងឆ្នាំ២០២៦ថ្មីមួយបន្ថែមទៀត របស់ប្រជាជាតិខ្មែរយើង។ សំណង់អគារថ្មីនៃព្រឹទ្ធសភា ដែលត្រូវបានកសាងឡើងក្រោមការផ្តួចផ្តើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានប្រសិទ្ធនាមថា "**វិមានសាមគ្គីភាព**" បង្ហាញឱ្យឃើញពីគុណតម្លៃ និងទស្សនវិជ្ជាដឹកនាំស្ទួលរបស់ថ្នាក់ដឹកនាំខ្មែរ ដែលយល់យ៉ាងច្បាស់ថាការបង្រួបបង្រួមជាតិ និងសាមគ្គីភាពជាតិ គឺជាសសរទ្រូងដ៏រឹងមាំនៃ សន្តិភាព ស្ថិរភាព និងភាពរីកចម្រើនដ៏យូរអង្វែងរបស់កម្ពុជា ។

**ខ្ញុំ** សូមនាំមកនូវព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ និងសេចក្តីនឹករលឹកដ៏ជ្រាលជ្រៅបំផុតអំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ជាទីបំផុតមកជូនសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិ និងប្រិយមិត្តបរទេសទាំងអស់ ដែលមានព្រះវត្តមាន និងវត្តមាននៅទីនេះ ។

**ខ្ញុំ** សូមកោតសរសើរ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលផ្តួចផ្តើមគំនិតបង្កើតទស្សនទាន និងដឹកនាំការកសាង "**វិមានសាមគ្គីភាព**"នៅលើទីតាំងជ័យភូមិជាញជ័យដ៏ពិសិដ្ឋនេះឡើង សម្រាប់ទុកជាបេតិកភណ្ឌជាតិដ៏វិសេសវិសាលមួយទៀតរបស់ជាតិ។ វិមាននេះក៏ជានិមិត្តរូបនៃការតភ្ជាប់មោទនភាពបច្ចុប្បន្ន ទៅនឹងភាពថ្កុំថ្កើង រុងរឿងរបស់មហាអាណាចក្រខ្មែរនាពេលអតីតកាល ដែលធ្លាប់មានអរិយធម៌ចំណាស់ត្រចះត្រចង់ ឧត្តុង្គឧត្តម និងមានកិត្យានុភាពល្បីរន្ទឺនៅក្នុងតំបន់ និងនៅលើសកលលោក។ យើងអាចសន្និដ្ឋានបានថា "**វិមានសាមគ្គីភាព**" នឹងមិនត្រឹមតែជានិមិត្តរូប

នៃសាមគ្គីជាតិប៉ុណ្ណោះទេ ប៉ុន្តែអគារនេះនឹងជួយលើកកម្ពស់កិត្យានុភាពជាតិនៅលើឆាកអន្តរជាតិ នាពេលបច្ចុប្បន្ន និងទៅអនាគត ព្រមទាំងជួយបន្ថែមសោភ័ណភាព និងភាពចម្រុះអមដោយសំណង់អគារប្រវត្តិសាស្ត្រជាច្រើននៅក្នុងវិមានរដ្ឋចំការមន ដែលជាកេរដំណែលមរតកនៃស្ថាបត្យកម្ម និងជាស្នាព្រះហស្តដ៏ថ្លៃថ្លាបំផុតនៃ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ជាទីបំផុត ក្នុងពេលដែលព្រះអង្គនៅគង់ព្រះជន្ម និងបំពេញព្រះរាជកិច្ចនៅទីនេះ ។

**ខ្ញុំ** សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីព្រឹទ្ធសភា ដែលបានផ្តល់របាយការណ៍ប្រកបដោយខ្លឹមសារដ៏មានសារៈសំខាន់អំពីទស្សនទានដំណើរការសាងសង់។ **ខ្ញុំ** ពិតជាមានហឫទ័យរំភើបជាអនេក ពេលបានទតឃើញ **"វិមានសាមគ្គីភាព"**ដ៏ស្កឹមស្កៃ ដែលត្រូវបានកសាងរួចរាល់ជាស្ថាពរ ក្នុងទម្រង់សិល្បៈស្ថាបត្យកម្មខ្មែរដ៏ល្អវិចិត្របែបនេះ ។

សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ

ជាសច្ចធម៌មិនអាចប្រកែកបាន ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យ គតិបណ្ឌិតដ៏ឆ្នើមឈ្លាសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញ និងដឹកនាំអនុវត្តប្រកបដោយជោគជ័យនូវ **"នយោបាយឈ្នះ-ឈ្នះ"** ហើយជាបន្តបន្ទាប់មកទៀត ចាប់ពី **"យុទ្ធសាស្ត្រត្រីកោណ"** រហូតដល់ **"យុទ្ធសាស្ត្រចតុកោណ"** និងគោលនយោបាយកែទម្រង់មុតស្រួចនិងស៊ីជម្រៅលើគ្រប់វិស័យ, សេដ្ឋកិច្ចសង្គម ធ្វើឱ្យកម្ពុជាទទួលបានការអភិវឌ្ឍ និងរីកចម្រើនជាលំដាប់ ក៏ដូចជាបានផ្លាស់ប្តូរមុខមាត់ថ្មីគួរជាទីមោទនៈ។ ទាំងអស់នេះគឺមកពីយើងទាំងអស់គ្នាមានមហាសាមគ្គីជាតិជាធ្លុងមួយ ក្រោមម្លប់សន្តិភាពដ៏រឹងមាំ និងយូរអង្វែងក្នុងផ្ទៃប្រទេស កំណើនសេដ្ឋកិច្ចខ្ពស់ជាប់មិនដាច់ ក្នុងចិរវេលាជិត២ទសវត្សរ៍ដែលពុំធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា បាននិងកំពុងផ្តល់ផ្លែផ្កា ដែលធ្វើឱ្យសមិទ្ធផលស្មានមិនដល់ជាច្រើនលេចចេញជារូបរាងឡើង។ ដោយឡែកសម្រាប់នីតិកាលទី៥នៃព្រឹទ្ធសភាក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននាំមកនូវសមិទ្ធផលដ៏ធំធេងបន្ថែមទៀតក្នុងការការពារ **ជាតិ សាសនា ព្រះមហាក្សត្រ** និងការពង្រឹងឯកភាពជាតិរក្សាការពារអធិបតេយ្យភាពជាតិដ៏ថ្លៃថ្លា និងអរិយធម៌អង្គរដ៏បវរនៃយើង។

ក្នុងឱកាសដ៏ប្រសើរនេះ **ខ្ញុំ** សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** ជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ **ព្រះមហាក្សត្រ** នៅក្នុងគ្រប់កាលៈទេសៈ ដែលប្រទេសជាតិត្រូវទទួលរងនូវការរំលោភបំពាន និងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរពីសំណាក់បរទេសនាពេលកន្លងទៅ **សម្តេច**បានដឹកនាំ និងនៅរួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋ ជាពិសេសជាមួយបងប្អូនវីរយុទ្ធជនជាតិយើង នៅគ្រប់លំដាប់ថ្នាក់ និងនៅតាមទីតាំងបញ្ជាការជួរមុខតាមបណ្តោយព្រំដែនកម្ពុជា ព្រមទាំងបានរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ប្រឹក្សាយោបល់យុទ្ធសាស្ត្រ ផ្តល់ការលើកទឹកចិត្ត គាំទ្រគ្រប់បែបយ៉ាង និងគ្រប់ទិដ្ឋភាពដោយគ្មានពេលសម្រាក ទាំងយប់-ថ្ងៃ ដើម្បីបុព្វហេតុតែមួយគត់គឺការការពារឱ្យខាងតែបាននូវបូរណភាពទឹកដី និងដែនអធិបតេយ្យភាពជាតិយើង ។

**ខ្ញុំ** ក៏សូមសម្តែងនូវការកោតស្ញប់ស្ញែង និងកោតសរសើរយ៉ាងក្រៃលែងចំពោះវីរភាពរបស់វីរយុទ្ធជនកម្ពុជាគ្រប់រូប ដែលបានប្រយុទ្ធតស៊ូយ៉ាងខ្លាំងក្លា អង់អាចក្លាហាននៅគ្រប់សមរភូមិ ដើម្បីបុព្វហេតុការពារជាតិ ការពារទឹកដី និងការពារប្រជាជន ក៏ដូចជាប្រជាជនកម្ពុជានៅទូទាំងប្រទេសដែលបានរួបរួមជាកម្លាំងមហាសាមគ្គីជាតិយ៉ាងរឹងមាំ និងមានឯកភាពជាតិខ្ពស់ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងទេពកោសល្យដ៏ឧត្តុង្គឧត្តមរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមាន**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខដឹកនាំកំពូលក្នុងការប្រយុទ្ធតស៊ូលើគ្រប់សមរភូមិ ទាំងសមរភូមិនយោបាយ សមរភូមិការទូត សមរភូមិយោធា និងសមរភូមិច្បាប់ ដើម្បីការពារជាតិ ការពារអធិបតេយ្យភាពជាតិ ការពារបូរណភាពទឹកដី និងការពារប្រជាជនកម្ពុជារបស់យើង ។

ជាទីបញ្ចប់ **ខ្ញុំ** សូមជូនពរ សម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងបងប្អូនជនរួមជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា សូមបានប្រកបដោយព្រះពុទ្ធពរគ្រប់ប្រការជានិច្ចនិរន្តរ៍តទៅ និងសូមប្រកាសសម្ពោធដាក់ឱ្យប្រើប្រាស់នូវ **វិមានសាមគ្គីភាព** នេះឱ្យដំណើរការចាប់ពីពេលនេះតទៅ ៕

សូមអរគុណ